**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២០/០២/២០០៩ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០៩

**ជម្រាបមក**

**ឯកឧត្តម សម រង្ស៊ី តំណាងរាស្ត្រ និងជាប្រធានគណបក្ស សម រង្ស៊ី**

**<u>កម្មវត្ថុ</u>** : រឿងទាក់ទងនឹងសំណើសុំពិនិត្យធម្មនុញ្ញភាពលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ១០០/០០៥/២០០៨ កបធ.ច ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៨

**<u>យោង</u>** : លិខិតរបស់ឯកឧត្តម គ្មានលេខ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០៩ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើរបស់ឯកឧត្តមរួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកសំណើរបស់ឯកឧត្តមមកពិភាក្សាបានឡើយ ពីព្រោះម្ចាស់សំណើពុំមានគុណវុឌ្ឍិស្របតាមទម្រង់ដែលមានចែងក្នុងមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

សូមឯកឧត្តមទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**